## ខ្ញុំពុំមានការរ៉ាប់រងសុខភាពទេ។ តើខ្ញុំអាចទទួលការថែទាំសុខភាព ឥឡូវនេះ

- **Healthy Way LA (HWLA)–** នេះគឺជាកម្មវិធីឥតចេញថ្លៃ ដែលអ្នកអាចដាក់ពាក្យសុំនៅឥឡូវនេះ។ ស្វែងយល់ ថែមទៀតនៅ **www.ladhs.org/hwla** ឬទូរស័ព្ទទៅលេខ **1-877-333-4952**។
- **Medi-Cal–**ឥឡូវនេះ កម្មវិធីនេះគឺសំរាប់ក្មេងៗ និងមាតាបិតា មានប្រាក់ចំណូលតិច, ស្ត្រីមានផ្ទៃពោះ, ព្រឹទ្ធវ័យ និងមនុស្សពិការ។ បើអ្នកឋិតនៅក្នុងប្រភេទណាមួយទាំងនេះ អ្នកអាចនឹងដាក់ពាក្យសុំ Medi-Cal នៅឥឡូវនេះបាន។ ទូរស័ព្ទទៅលេខ **1-877-597-4777** ឬមើល **dpss.lacounty.gov/dpss/health**
- **កម្មវិធី Healthy Kids របស់ L.A. Care –**នេះជាកម្មវិធីធានារ៉ាប់រងសុខភាពមានតម្លៃទាប សំរាប់ក្មេងៗដល់ទៅអាយុ 5 ឆ្នាំ ដែលគ្មានសិទ្ធិទទួលកម្មវិធីផ្សេងៗទៀត ពីព្រោះតែសញ្ជាតិ លំនៅដ្ឋាន ឬប្រាក់ចំណូលគ្រួសាររបស់គេខ្ពស់ពេក។ មើល **www.lacare.org/potentialmembers/healthprograms/healthy-kids** ឬទូរស័ព្ទ : **1-888-452-2273**។
- **Family PACT** ផ្តល់ការរៀបចំគំរោងគ្រួសារ និងរបៀបបង្ការមានកូនដោយឥតគិតថ្លៃ សំរាប់ស្ត្រី និងបុរស មានប្រាក់ចំណូលតិច។ មើល **www.familypact.org** ឬរស័ព្ទទៅលេខ **1-800-942-1054**។

****វាឥតអស់ថ្លៃទេឡើយ ដើម្បីដាក់ពាក្យសុំកម្មវិធីទាំងនេះ!****

### ចុះបើសិនខ្ញុំពុំមានសិទ្ធិទទួលកម្មវិធីទាំងនេះ?

✦ **គ្លីនិកតាមខោនធី និងសហគមន៍**
គឺនៅទីនេះដើម្បីជួយនៅឥឡូវនេះ និងក្នុងឆ្នាំ 2014។ អ្នកមូលដ្ឋាននៅខោនធី Los Angeles ដែលមិនអាចនៅក្នុងកម្មវិធីផ្សេងទៀត ពីព្រោះតែ សញ្ជាតិ លំនៅដ្ឋាន អាយុ ឬមូលហេតុផ្សេងទៀត អាចរកគ្លីនិកដែលស្ថិតនៅជិតគេ នៅឯ:**www.ladhs.org/wps/portal/clinicsearch**។

## ខ្ញុំមានការរ៉ាប់រងសុខភាពរួចហើយ។ តើកំណែសុខភាព នឹងប៉ះពាល់ដល់ខ្ញុំយ៉ាងណា?

- **ខ្ញុំមាន Medi-Cal ហើយ!**
អ្នកអាចរក្សាការធានារ៉ាប់រងសុខភាព Medi-Cal របស់អ្នក។ ស្រាវជ្រាវថែមទៀតនៅឯ : **dpss.lacounty.gov/dpss/health** ឬទូរស័ព្ទទៅលេខ **1-877-597-4777**។
- **ខ្ញុំមាន Medicare ហើយ!** អ្នកអាចរក្សា Medicare របស់អ្នក។ ច្បាប់កំណែសុខភាព អាចនឹងបន្ទាបតម្លៃថ្នាំពេទ្យរបស់អ្នក។ អ្នកនឹងមិនបាច់បង់ថ្លៃថែទាំបង្ការ ដូចជាការត្រួតពិនិត្យរោគមហារីក, ចាក់ថ្នាំការពាររោគ, ចាក់ថ្នាំការពារគ្រុនផ្តាសាយធំ, និងការជួបពិនិត្យផាសុកភាព។ ស្រាវជ្រាវថែមទៀតនៅឯ : **www.medicare.gov** ឬទូរស័ព្ទទៅលេខ **1-800-633-4227**។
- **ខ្ញុំមានការធានារ៉ាប់រងតាមរយៈការងាររបស់ខ្ញុំហើយ!**
អ្នកអាចរក្សាការធានារ៉ាប់រងសុខភាពរបស់អ្នក។ ច្បាប់សុខភាពមិនធ្វើឲ្យនិយោជករបស់អ្នក ផ្លាស់ប្តូរការធានារ៉ាប់រងរបស់អ្នកឡើយ។ ស្រាវជ្រាវថែមទៀត ដោយទាក់ទងគំរោងសុខភាព ឬនិយោជករបស់អ្នក។
- **ខ្ញុំទិញការធានារ៉ាប់រងដោយខ្លួនឯង!**
អ្នកនៅតែអាចទិញការធានារ៉ាប់រងខ្លួនឯងបាន។ ចាប់ផ្តើមនៅខែតុលា អ្នកអាចរកទិញការធានារ៉ាប់រងសុខភាពដែលមានតម្លៃទាបជាង តាមរយៈ ***Covered California*** (ការរ៉ាប់រងចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា 2014)។ មើល **www.coveredca.com** ឬទូរស័ព្ទទៅលេខ **1-888-975-1142**។

### ចុះបើសិនខ្ញុំមាន Healthy Way LA (HWLA)?

- នៅថ្ងៃទី 1 ខែមករា 2014 នេះ Healthy Way LA នឹងក្លាយជា Medi-Cal។ អ្នកនឹងទទួលសំបុត្រក្នុងពេលឆាប់ៗ ដែលពន្យល់ពីការផ្លាស់ប្តូរ។ ស្វែងយល់ថែមទៀតនៅ **www.ladhs.org/hwla** ឬទូរស័ព្ទទៅលេខ **1-877-333-4952**។

# កំណែសុខាភិបាល

*និង អ្នក...*



Health Services
LOS ANGELES COUNTY

## តើនៅតែត្រូវការជួយឬ?

សូមទូរស័ព្ទទៅ មណ្ឌលសុខភាព អតិថិជន
នៃសេវាខាងច្បាប់តាមភូមិឋាន **1-800-896-3202**



## ខ្ញុំពុំមានការធានារ៉ាប់រងទេ។ តើមានជំរើសថ្មីអ្វីសំរាប់ខ្ញុំ ក្នុងឆ្នាំ 2014?

## តើកំណែសុខាភិបាល ជាអ្វី?

- វាជាច្បាប់នៃរដ្ឋបាលសហព័ន្ធ ដែលបានចាប់ផ្តើមក្នុងឆ្នាំ 2010។ វាផ្លាស់ប្តូររបៀបខ្លះ ដែលមនុស្សទទួលការថែទាំសុខភាពនៅក្នុងសហរដ្ឋអាមេរិក
- វាក៏ហៅថា *ក្រិត្យថែទាំអាចផ្គត់ផ្គង់បាន* ឬ *Obamacare* ដែរ។

### តើអ្វីខ្លះដែលបានផ្លាស់ប្តូររួចហើយ?

- ការរ៉ាប់រងសុខភាព រួមបញ្ចូលនូវការពិនិត្យសុខភាពទូទៅ និងការថែទាំបង្ការភាគច្រើន ដោយឥតគិតថ្លៃ
- មនុស្សវ័យក្មេង អាចនៅជាមួយការធានារ៉ាប់រងសុខភាពនៃមាតាបិតារបស់គេ រហូតដល់ពេលគេមានអាយុ 26 ឆ្នាំ។
- ក្រុមហ៊ុនធានារ៉ាប់រង មិនអាចលុបចោលការធានារ៉ាប់រងសុខភាពរបស់អ្នកបានឡើយ បើសិនអ្នកឈឺថ្កាត់
- ក្រុមហ៊ុនធានារ៉ាប់រង មិនអាចបដិសេធការថែទាំក្មេងៗ ពីព្រោះគេឈឺថ្កាត់នៅឥឡូវនេះ ឬបានឈឺថ្កាត់នៅពេលកន្លងមកឡើយ
- ក្រុមហ៊ុនធានារ៉ាប់រង ត្រូវតែចំណាយ 80% នៃប្រាក់របស់អ្នក( ថ្លៃបង់ធានារ៉ាប់រង និងការរួមបង់ប្រាក់របស់អ្នក ) ទៅលើការថែទាំសុខភាព ឬឲ្យប្រាក់អ្នកវិញ

### តើនឹងមានការផ្លាស់ប្តូរអ្វី កើតឡើងនៅថ្ងៃទី 1 ខែមករា 2014?

- របៀបថ្មី សំរាប់ឲ្យមនុស្សទទួលការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬ មានតម្លៃថោក
- មនុស្សភាគច្រើន ត្រូវតែមានការធានារ៉ាប់រងសុខភាព ឬគេនឹងទទួលពិន័យប្រាក់
- ក្រុមហ៊ុនធានារ៉ាប់រង មិនអាចបដិសេធការថែទាំអ្នកណាម្នាក់ ពីព្រោះគេឈឺថ្កាត់នៅឥឡូវនេះ ឬបានឈឺថ្កាត់នៅពេលកន្លងមកឡើយ
- ក្រុមហ៊ុនធានារ៉ាប់រង មិនអាចទារថ្លៃពីអ្នកថែមទៀត ឬកំរិតចំនួនប៉ុន្មានគេនឹងបង់ថ្លៃ ពីព្រោះអ្នកឈឺថ្កាត់ឡើយ
- យុវវ័យជាអតីតៈកូនចញ្ចឹម ដែលធ្លាប់មាន Medi-Cal នៅអាយុ 18 ឆ្នាំ នឹងមានសិទ្ធិទទួល Medi-Cal រហូតដល់អាអាយុ 26 ឆ្នាំ

**MEDI-CAL:** កម្មវិធី Medicaid របស់រដ្ឋកាលីហ្វ័រនីញ៉ា—សំរាប់មនុស្សដែលមានប្រាក់ចំណូលតិច។ បច្ចុប្បន្ននេះ Medi-Cal គឺជាការធានារ៉ាប់សុខភាពសំរាប់ក្មេងៗ, មាតាបិតា, ស្ត្រីមានផ្ទៃពោះ, ព្រឹទ្ធវ័យ, និងមនុស្សពិការ ដែលមានប្រាក់ចំណូលតិច។

### តើអ្វីខ្លះ ដែលកំពុងតែផ្លាស់ប្តូរ?

- **ថ្ងៃទី 1 ខែមករា 2014 :** មនុស្សច្រើនទៀតនឹងអាចទទួល Medi-Ca។ កំរិតប្រាក់ចំណូលនឹងខ្ពស់ជាង ហើយមនុស្សពេញវ័យដែលគ្មានកូន នឹងអាចដាក់ពាក្យសុំបាន! (មើលតារាងខាងក្រោម)។
- **តើនេះសំរាប់ខ្ញុំឬ?** ស្រាវជ្រាវឲ្យដឹង! សូមទូរស័ព្ទទៅ Healthy Way LA (HWLA) ក្រែងលោអ្នកអាចដាក់ពាក្យសុំនៅឥឡូវនេះ។ មើល **www.ladhs.org/hwla** ឬ ទូរស័ព្ទទៅលេខ **1-877-333-4952**។

**COVERED CALIFORNIA:** ជាកន្លែងទីផ្សារ តាមអ៊ិនទ័រណិត ដែលមនុស្សអាចរកទិញការធានារ៉ាប់រងសុខភាព និងស្រាវជ្រាវឲ្យដឹង បើសិនគេមានសិទ្ធិទទួលជំនួយប្រាក់ ដើម្បីធ្វើឲ្យការធានារ៉ាប់រងរឹតតែអាចផ្គត់ផ្គង់បាន។ ទិញតាមអ៊ិនទ័រណិត ឬទូរស័ព្ទ។

### តើវាចាប់ផ្តើមនៅពេលណា?

- **ខែតុលា 2013 :** ការបើកចុះឈ្មោះ នឹងចាប់តាំងពីថ្ងៃទី 1 ខែតុលា 2013 រហូតដល់ថ្ងៃទី 31 ខែមីនា 2014។ ត្រូវចុះឈ្មោះឲ្យទាន់ថ្ងៃទី 15 ខែធ្នូ ដើម្បីឲ្យការធានារ៉ាប់រងចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា 2014!

### តើនេះសំរាប់ខ្ញុំឬ?

- ស្រាវជ្រាវឲ្យដឹង នៅឯ : **www.coveredca.com** ឬទូរស័ព្ទទៅលេខ **1-888-975-1142**។

| បើសិនអ្នកជា *... | | ក្នុងឆ្នាំ 2014 អ្នកអាចនឹងមានសិទ្ធិទទួល ... |
|---|---|---|
| | បុគ្គលម្នាក់រកប្រាក់បានតិចជាង $15,856 | Medi-Cal ជាកម្មវិធីនៃរដ្ឋាភិបាល ឥតគិតថ្លៃ។ |
| | បុគ្គលម្នាក់រកប្រាក់បានពី $15,856 ទៅ $28,726 | ជួយបង់តម្លៃនៃការចំណាយ-ពី-ហោប៉ៅ ដូចជាការកាត់ថ្លៃ និងថ្លៃរួមបង់ និងឥណទានពន្ធដារ (ប្រាក់ឧបត្ថម្ភ) ដែលនឹងបន្ទាបចំនួននៃថ្លៃបង់ធានារ៉ាប់រងប្រចាំខែរបស់អ្នក។** |
| | បុគ្គលម្នាក់រកប្រាក់បានពី $28,725 ទៅ $45,960 | ឥណទានពន្ធដារ ដែលនឹងបន្ទាបចំនួននៃថ្លៃបង់ធានារ៉ាប់រងប្រចាំខែរបស់អ្នក។** |
| | បុគ្គលម្នាក់រកប្រាក់បានលើសពី $45,960 | អ្នកគ្មានសិទ្ធិទទួលជំនួយពីរដ្ឋាភិបាលទេ ប៉ុន្តែអ្នកនៅតែអាចរកទិញការធានារ៉ាប់រងតាមរយៈ Covered California។ |
| | គ្រួសារមួយមានគ្នាបួននាក់ រកប្រាក់បានតិចជាង $32,499 | Medi-Cal ជាកម្មវិធីនៃរដ្ឋាភិបាល ឥតគិតថ្លៃ។ |
| | គ្រួសារមួយមានគ្នាបួននាក់ រកប្រាក់បានពី $32,499 ទៅ $58,875 | ជួយបង់តម្លៃនៃការចំណាយ-ពី-ហោប៉ៅ ដូចជាការកាត់ថ្លៃ និងថ្លៃរួមបង់ និងឥណទានពន្ធដារ (ប្រាក់ឧបត្ថម្ភ) ដែលនឹងបន្ទាបចំនួននៃថ្លៃបង់ធានារ៉ាប់រងប្រចាំខែរបស់អ្នក។** |
| | គ្រួសារមួយមានគ្នាបួននាក់ រកប្រាក់បានពី $58,875 ទៅ $94,200 | ឥណទានពន្ធដារ ដែលនឹងបន្ទាបចំនួននៃថ្លៃបង់ធានារ៉ាប់រងប្រចាំខែរបស់អ្នក។** |
| | គ្រួសារមួយមានគ្នាបួននាក់ រកប្រាក់បានលើសពី $94,200 | អ្នកគ្មានសិទ្ធិទទួលជំនួយពីរដ្ឋាភិបាលទេ ប៉ុន្តែអ្នកនៅតែអាចរកទិញការធានារ៉ាប់រងតាមរយៈ Covered California។ |

* *កំរិតប្រាក់ចំណូល យោងទៅលើឆ្នាំ 2013*

** *អ្នកត្រូវតែចុះឈ្មោះតាមរយៈ Covered California ទើបមានសិទ្ធិទទួលឥណទានពន្ធដារបាន*

**តើមិនប្រាកដថាអ្នកមានសិទ្ធិទទួលឬ?** សូមទូរស័ព្ទទៅ មណ្ឌលអតិថិជន នៃសេវាខាងច្បាប់តាមភូមិឋាន : **1-800-896-3202**

**វាឥតអស់ថ្លៃឡើយ ដើម្បីដាក់ពាក្យសុំ-កុំបង់ឲ្យអ្នកណាម្នាក់ ដើម្បីជួយអ្នក!**